**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិនៃកម្ពុជា**
**លេខៈ ......... ប្រ.ក**

# ប្រកាស
# ស្តីពី
# ប្រតិបត្តិការលើមូលប័ត្ររបស់ធនាគារ
# ដែលមានអាជ្ញាប័ណ្ណ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

~~~~~~~~~

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ ធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រិត្យលេខ ជស/រកត/ ០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃ ធនាគារជាតិនៃកម្ពុជា
- យោងតាមប្រកាសលេខ ធ៨-៩៩-១៤៨ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីរចនាសម្ព័ន្ធរបស់នាយកដ្ឋានត្រួតពិនិត្យ និង មុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ
~~~~~~~~~

# សំ រេ ច

## ប្រការ ១:

ធនាគារជាតិនៃកម្ពុជាគាំទ្រនិងបង្កលក្ខណៈអំណោយផលដល់ការរីកលូតលាស់និងកិច្ចអភិវឌ្ឍន៍នៃទីផ្សារមូលប័ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលការណ៍សុវត្ថិភាព ភាពរឹងមាំ និងប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងសំរបសំរួលនិតិវិធីគណនេយ្យ និងប្រតិបត្តិការរបស់ខ្លួន ក្នុងគោលបំណងសំរួលការផ្តល់ឥណទាន និងការជួញដូរមូលប័ត្រជាអន្តរធនាគារ ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជានឹងអនុវត្តនូវស្តង់ដារពិសេសសំរាប់ធ្វើការត្រួតពិនិត្យធនាគារទាំងឡាយដែលដើរតួជាជើងសារការី ឬជាប្រតិបត្តិករមូលប័ត្រ ។

## ប្រការ ២:

ធនាគារត្រូវបានចាត់ទុកថាជាប្រតិបត្តិករជើងសារការីឬជាប្រតិបត្តិករមូលប័ត្រ បើធនាគារនោះផ្តល់ការធានា ឬជួញដូរ ឬធ្វើប្រព្រឹត្តិកម្មមូលប័ត្រ ។ ទោះបីពុំទាន់មានអង្គភាពជាផ្លូវការសំរាប់គ្រប់គ្រងសកម្មភាពប្រតិបត្តិការលើមូលប័ត្រក្តី ក៏មិនមែនជាបុព្វបទដែលធ្វើអោយរាំងស្ទះដល់ការកំណត់ធនាគារមួយថាជាប្រតិបត្តិករមូលប័ត្រនោះឡើយ ។ ប្រសិនបើការទិញនិងលក់មូលប័ត្ររយៈពេលខ្លីតាមរូបភាពដដែល១បង្ហាញឱ្យប្រតិបត្តិករមូលប័ត្រឬវិនិយោគិនដទៃទៀតយល់ឃើញថា ធនាគារធ្វើប្រតិបត្តិការលើមូលប័ត្រ ធនាគារនោះត្រូវបានចាត់ទុកថាធ្វើសកម្មភាពជួញដូរមូលប័ត្រ ដោយពុំគិតដល់ផ្នែកណាមួយនៃធនាគារជាអ្នកចាត់ចែងដំណើរប្រតិបត្តិការទាំងនោះឡើយ ។

## ប្រការ ៣:

ធនាគារអាចចូលរួមក្នុងការធ្វើសកម្មភាពជួញដូរមូលប័ត្រ ដូចមានចែងនៅក្នុងជំពូកទីមួយ មាត្រា ៣ និង មាត្រា ៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ធនាគារជាតិនៃកម្ពុជា និងគណៈកម្មការពិសេស ដូចមានចែងនៅក្នុងមាត្រា ៦ និង មាត្រា ៧ នៃច្បាប់នេះដែរ នឹងត្រូវចេញបទបញ្ជា ដើម្បីគ្រប់គ្រងសកម្មភាពទាំងនោះ ។

## ប្រការ ៤៖

ការសំរបសំរួលនិតិវិធីប្រតិបត្តិការនិងគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជា រួមមានការអនុញ្ញាតិឱ្យធនាគារ អាចផ្ទេរមូលនិធិពីគណនីចរន្តរបស់ខ្លួនទៅកាន់គណនីចរន្តរបស់ធនាគារដទៃនៅធនាគារជាតិនៃកម្ពុជា តាមវិធីប្រើបញ្ជាទូទាត់តាមទូរស័ព្ទជាលើកដំបូងទៅធនាគារជាតិនៃកម្ពុជា ដោយមានការសួរបញ្ជាក់តបវិញ ។ ដើម្បីអនុវត្តវិធីនេះ ធនាគារបញ្ជាផ្ទេរប្រាក់ និងធនាគារទទួលប្រាក់ ចាំបាច់ត្រូវធ្វើកិច្ចព្រមព្រៀងគោល ដែលត្រូវផ្ញើជូនមកធនាគារជាតិនៃកម្ពុជាជាមុន ។ កិច្ចព្រមព្រៀងនេះត្រូវចែងអំពីប្រការទាំងឡាយបង្ហាញពីការស្រុះស្រួលគ្នាធ្វើប្រតិបត្តិការបែបនេះ និងមានការអនុញ្ញាតិពីក្រុមប្រឹក្សាភិបាលរបស់សាម៉ីធនាគាររៀង១ខ្លួនផងដែរ ។

លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជានឹងបង្កើតប្រព័ន្ធចុះបញ្ជីសំរាប់មូលប័ត្ររបស់រដ្ឋាភិបាលនៅពេលណាដែលមូលប័ត្រនេះត្រូវបានចេញផ្សាយ ។ កិច្ចព្រមព្រៀងផ្ទេរតាមទូរស័ព្ទដូចគ្នាខាងលើសំរាប់ការជួញដូរមូលប័ត្ររបស់រដ្ឋាភិបាលក្នុងចំណោមធនាគារ នឹងត្រូវបង្កើតឡើងនៅពេលនោះ ។

## ប្រការ ៥៖

ធនាគារជាតិនៃកម្ពុជានឹងធ្វើការត្រួតពិនិត្យលើសកម្មភាពរបស់ធនាគារ ដែលធ្វើសកម្មភាពជួញដូរមូលប័ត្រ ។ និតិវិធីនៃការត្រួតពិនិត្យរួមមានការត្រួតពិនិត្យមើលក្រុមប្រឹក្សាភិបាលនិងការគ្រប់គ្រងការត្រួតពិនិត្យលើគោលនយោបាយនិងក៏រិតហានិភ័យ ការថែរក្សាឯកសារកត់ត្រានិងភាពត្រឹមត្រូវនៃប្រតិបត្តិការ ការអនុវត្តការជួញដូរនិងការបែងចែកភារៈកិច្ច ការងារបណ្តុះបណ្តាលនិងកម្មវិធីផ្តល់កំរៃដល់ប្រតិបត្តិករនិងបុគ្គលិក ការកាន់កាប់មូលប័ត្រនិងការកត់ត្រាការជួញដូរ និងទិដ្ឋភាពដទៃទៀតនៃប្រតិបត្តិការទាំងឡាយដែលពាក់ព័ន្ធ ។ របកគំហើញនៃការត្រួតពិនិត្យបែបនេះ អាចជាផ្នែកមួយនៃការត្រួតពិនិត្យជារួមទៅលើធនាគារ ឬ អាចមានលក្ខណៈឯករាជ្យដាច់ចេញពីរបាយការណ៍ត្រួតពិនិត្យដទៃទៀត ។

**ប្រការ ៦:**

រាល់របាយការណ៍ត្រួតពិនិត្យទាំងអស់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជាគឺជាកម្មសិទ្ធិផ្តាច់មុខរបស់ធនាគារជាតិនៃកម្ពុជា ហើយមិនអាចថតចំលង ឬបញ្ជូនដោយគ្មានការឯកភាពពីធនាគារជាតិនៃកម្ពុជាឡើយ លើកលែងតែក្នុងករណីដែលច្បាប់អនុញ្ញាតិ ។

**ប្រការ ៧:**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និង គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនៃធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឹងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨:**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០២

**ទេសាភិបាល**

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពតិមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"